ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ

ឆ្នាំ ២០១៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ: ...០៧៤....... ប្រក/អសណ

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតជួសជុលសំណង់អគារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- បានឃើញប្រកាសរួមលេខ ១២២៩ ប្រក.មផ.ដនស រវាងក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការទប់ស្កាត់ការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសពីលិខិតអនុញ្ញាត
- តាមការចាំបាច់របស់ក្រសួង

## សម្រេច



អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet Com. Kh

# ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណង៖

- ផ្តល់ភាពស្របច្បាប់នៃសំណង់
- ធានាសុវត្ថិភាពលើការងារជួសជុលកែលម្អសំណង់អគារ
- បង្កើនការជឿទុកចិត្តពីសាធារណជននិងម្ចាស់សំណង់លើគុណភាពសំណង់តាមរយៈការតាមដានត្រួតពិនិត្យរបស់អ្នកបច្ចេកទេសជំនាញលើការជួសជុលអគារ ។

**ប្រការ៣.-**

ប្រកាសនេះមានគោលដៅដូចតទៅ ៖

- ទប់ស្កាត់ការជួសជុលសំណង់អគារដែលគ្មានលិខិតអនុញ្ញាតជួសជុល ឬខុសពីលិខិតអនុញ្ញាតជួសជុល
- ពង្រឹងអនុវត្តការងារបទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសុវត្ថិភាពសណ្តាប់ធ្នាប់ សោភ័ណភាព គុណភាពសំណង់ បរិស្ថាននិងជៀសវាងផលប៉ះពាល់ផ្សេងៗបណ្តាលមកពីការជួសជុលកែលម្អសំណង់អគារដែលមិនស្របតាមគំនូរប្លង់ នគរូបនីយប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស រចនាសម្ព័ន្ធក្រោមដី និងឯកសារនានាដែលបានអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទនៅព្រះរាជាណាចក្រកម្ពុជាលើកលែងតែសំណង់ជាភសាស្ត្រ សំណង់ស្ពានថ្នល់ សំណង់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ សំណង់ពាក់ព័ន្ធវិស័យការពារជាតិ រាល់ការជួសជុលអគារទាំងឡាយដែលមិនបណ្តាលឲ្យប៉ះពាល់ដល់សំណង់ជិតខាង ឬសមត្ថភាពគ្រឿងផ្គុំសំណង់ និងរាល់ការជួសជុលតូចតាច ។

**ប្រការ៤.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ មានន័យដូចតទៅ ៖

- ការជួសជុលសំណង់ សំដៅដល់ការជួសជុលនូវចំណែកណាមួយនៃសំណង់ដែលខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ
- គំនូរប្លង់ សំដៅដល់គំនូរប្លង់ស្ថាបត្យកម្មនិងប្លង់វិស្វកម្ម ដែលគូរដោយអ្នកបច្ចេកទេសជំនាញស្របតាមបទដ្ឋានបច្ចេកទេសសំណង់និងមានមាត្រដ្ឋានកំណត់ច្បាស់លាស់
- គ្រឿងផ្គុំសំណង់ សំដៅដល់រចនាសម្ព័ន្ធអគាររួមមាន គ្រឹះ សសរ ធ្នឹម កម្រាល គ្រឿងផ្គុំជំហូរជណ្តើរ ជញ្ជាំងរងបន្ទុក និងគ្រឿងផ្គុំសំណង់ផ្សេងទៀត ដែលគ្រោងឡើងសម្រាប់ទ្រទម្ងន់

- ស្ថាប័នមានសមត្ថកិច្ចឬស្ថាប័នជំនាញ សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- ស្ថាបត្យកម្ម សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារ និងការសាងសង់ទាំងក្នុងនិងក្រៅនៃសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេស និងតាមសំណុំសោភ័ណភាពដែលបានគ្រោងទុក ដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន
- អ្នកបច្ចេកទេសជំនាញ សំដៅដល់មន្ត្រីជំនាញរបស់រដ្ឋនិងអ្នកបច្ចេកទេសជំនាញរបស់ក្រុមហ៊ុន មានជាអាទិ៍ ស្ថាបត្យករ វិស្វករ អ្នកបច្ចេកទេសខាងវិស័យសំណង់
- អ្នកពាក់ព័ន្ធ សំដៅដល់អ្នកបច្ចេកទេសជំនាញ ក្រុមហ៊ុនត្រួតពិនិត្យការដ្ឋាន សហគ្រាសទទួលការសាងសង់ រូបវន្តបុគ្គលប្រចាំការដ្ឋាន ភ្នាក់ងារអង្កេតការដ្ឋាន និងអ្នកជិតខាង
- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់ក្រសួងស្ថាប័នរដ្ឋ ឬរដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិ
- ថ្ងៃធ្វើការ សំដៅដល់ថ្ងៃធ្វើការជាផ្លូវការកំណត់ដោយរាជរដ្ឋាភិបាល
- ការជួសជុលតូចតាច សំដៅដល់ការកោសលាប និង/ឬការសម្អាតខាងក្នុងអគារ ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ៥.-**

រូបវន្តបុគ្គលឬនីតិបុគ្គលមានសិទ្ធិស្នើសុំធ្វើការជួសជុលសំណង់អគារគ្រប់ប្រភេទលើកលែងតែសំណង់ណាដែលមានចែង លើកលែងក្នុងប្រការ៣ ។ លិខិតអនុញ្ញាតជួសជុល ត្រូវបានផ្ដល់ជូនដោយស្ថាប័នមានសមត្ថកិច្ចតាមការស្នើសុំរបស់ម្ចាស់សំណង់ ឬតំណាងស្របច្បាប់របស់ខ្លួន មុនចាប់ផ្ដើមដំណើរការជួសជុល។

ឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុល មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៦.-**

លិខិតអនុញ្ញាតជួសជុលត្រូវចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចរៀងៗខ្លួន។

ចំពោះអគារដែលបានសាងសង់មុនឆ្នាំ១៩៩៨ ការស្នើសុំជួសជុលអគារទាំងនោះមិនតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ទេ ។

ចំពោះអគារដែលបានសាងសង់ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់មុនពេលចេញប្រកាសនេះ ហើយគ្មានលិខិតអនុញ្ញាតសាងសង់និងគ្មានទំនាស់ ស្ថាប័នមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតជួសជុលជូនម្ចាស់សំណង់បាន ដោយម្ចាស់សំណង់ត្រូវធ្វើកិច្ចសន្យាធានានិងទទួលខុសត្រូវលើគុណភាពសំណង់ សុវត្ថិភាពអ្នកជិតខាង និងសណ្ដាប់ធ្នាប់សាធារណៈ។

ប្រការ៧.-

ចំពោះសំណង់អគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ននានា មុនពេលជួសជុល ម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតជួសជុលពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ លើកលែងតែសំណង់ដែលមានចែង លើកលែងក្នុងប្រការ៣នៃប្រកាសនេះ ឬសំណង់អគារណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក ។

ប្រការ៨.-

សេចក្តីជូនដំណឹងស្តីពីការស្នើសុំជួសជុល ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃចាប់ ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំដោយបិទផ្សាយនៅកន្លែងគ្រោងធ្វើការជួសជុល។ ក្នុងករណីចាំបាច់បន្ទាន់ ការជួសជុលអាចប្រព្រឹត្តទៅបានមុនផុតកំណត់រយៈពេល១៥(ដប់ប្រាំ) ថ្ងៃនៃសេចក្តីជូនដំណឹងខាងលើដោយយោងទៅលើការវាយតម្លៃរបស់ស្ថាប័នមានសមត្ថកិច្ច។

សេចក្តីជូនដំណឹងខាងលើត្រូវធ្វើឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាល ក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចសម្រេចលើលិខិតអនុញ្ញាតជួសជុលរៀងៗខ្លួន ។

## ជំពូកទី៣
## បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុល

ប្រការ៩.-

បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យកិច្ចការទូទៅ នៃអគ្គនាយកដ្ឋានសំណង់ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យកិច្ចការទូទៅត្រូវបញ្ជូនពាក្យស្នើសុំ និងឯកសារភ្ជាប់ទៅការិយាល័យជួសជុល និងថែទាំ នៃនាយកដ្ឋានសំណង់ ដើម្បីពិនិត្យ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំ និងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ

- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុលត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យជួសជុលនិងថែទាំ ត្រូវចុះពិនិត្យទីតាំងជួសជុលជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៨ (ប្រាំបី)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ពិនិត្យសម្រេច
- ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសំណង់ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។

**ប្រការ១០.-**

បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត មានដូចតទៅៈ

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន ០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថា ពាក្យស្នើសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារទាំងនេះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត ក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលពាក្យស្នើសុំ ដើម្បីពិនិត្យសម្រេចតាមសមត្ថកិច្ច
- ការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្តត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ក្នុងរយៈពេល០២(ពីរ)ថ្ងៃ ។ បើមានការខ្វះខាតអាចស្នើឲ្យ

អ្នកស្នើសុំលិខិតអនុញ្ញាតជួសជុលបំពេញបន្ថែមក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ( រយៈពេលនេះមិនរាប់បញ្ចូលក្នុងបរិបទនៃការចេញលិខិតអនុញ្ញាតជួសជុល១៥(ដប់ប្រាំ)ថ្ងៃទេ )

- ការិយាល័យសំណង់ត្រូវចុះពិនិត្យទីតាំងជាក់ស្តែងជាមួយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំមន្ទីរពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ ។

**ប្រការ១១.-**

បរិបទនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌមានដូចតទៅ ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរ ឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារភ្ជាប់ និងចេញបង្កាន់ដៃទទួលពាក្យនៅពេលដែលពិនិត្យឃើញថាពាក្យស្នើសុំនិងឯកសារភ្ជាប់មានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ។ ក្នុងករណីពាក្យស្នើសុំនៅមានលក្ខណៈពុំទាន់គ្រប់គ្រាន់ និង/ឬពុំទាន់ត្រឹមត្រូវ មន្ត្រីជំនាញត្រូវអញ្ជើញម្ចាស់សំណើមកបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់និង/ឬឲ្យបានត្រឹមត្រូវ
- នៅពេលម្ចាស់សំណើបានបំពេញឯកសារគ្រប់គ្រាន់ និង/ឬត្រឹមត្រូវហើយ មន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃទទួលពាក្យជូនអ្នកស្នើសុំ ។ រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃការស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវចាប់រាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវ
- ផ្នែកសំណង់នៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌត្រូវចុះពិនិត្យទីតាំងជាក់ស្តែងនិងធ្វើរបាយការណ៍ស្តីពីការងារជួសជុលក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ ជូនថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យនិងសម្រេច
- ថ្នាក់ដឹកនាំនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌពិនិត្យនិងសម្រេចលើពាក្យស្នើសុំជួសជុលក្នុងរយៈពេល០៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ។

ប្រការ១២.-

បរិបថនៃការចេញលិខិតអនុញ្ញាតជួសជុលក្នុងសមត្ថកិច្ចរបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌដែលទទួលបានប្រតិភូកម្មមុខងារមានដូចតទៅ៖

- ការស្នើសុំលិខិតអនុញ្ញាតជួសជុលមានរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យ
- ម្ចាស់សំណង់ ឬតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលនៅការិយាល័យច្រកចេញចូលតែមួយរបស់សាលាក្រុង ស្រុក ខណ្ឌ ដែលអគារស្នើសុំជួសជុលនោះតាំងនៅ ។ ពាក្យស្នើសុំនិងឯកសារភ្ជាប់ត្រូវធ្វើជាភាសាខ្មែរឬបកប្រែជាភាសាខ្មែរចំនួន០៧ច្បាប់ ។ ការទទួលពាក្យសុំត្រូវចុះកាលបរិច្ឆេទនិងចេញបង្កាន់ដៃទទួលពាក្យ
- រាល់ការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមបែបបទរដ្ឋបាលរបស់សាលាក្រុង ស្រុក ខណ្ឌ បន្ទាប់ពីបានទទួលយោបល់របស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ
- រាល់លិខិតអនុញ្ញាតជួសជុលដែលផ្តល់ដោយសាលាក្រុង ស្រុក ខណ្ឌ ច្រកចេញចូលតែមួយ ត្រូវបញ្ជូនច្បាប់ចម្លងនៃឯកសារទាំងនេះចំនួន០១ច្បាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ និង០១ច្បាប់មកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ។

**ប្រការ១៣.-**

លិខិតអនុញ្ញាតជួសជុល ត្រូវចាត់ទុកថាបានយល់ព្រម បើពុំមានចម្លើយណាមួយពីស្ថាប័នមានសមត្ថកិច្ចក្រោយពីថ្ងៃដាក់ពាក្យស្នើសុំចំនួន២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ ។

**ប្រការ១៤.-**

សោហ៊ុយសេវានៃការចេញលិខិតអនុញ្ញាតជួសជុល ត្រូវអនុវត្តតាមស្មារតីនៃប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ១៥.-**

លិខិតអនុញ្ញាតជួសជុលអស់សុពលភាព ប្រសិនបើការងារជួសជុលពុំដំណើរការក្នុងរយៈពេល០៣(បី)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតជួសជុល ។

លិខិតអនុញ្ញាតនេះ អាចពន្យាពេលបានតែមួយដងគត់ ប្រសិនបើម្ចាស់សំណង់មានមូលហេតុសមស្រប ។

ក្នុងករណីដែលការងារជួសជុលត្រូវបានផ្អាកលើសពី៣០(សាមសិប)ថ្ងៃ ដោយគ្មានមូលហេតុសមស្រប ស្ថាប័នមានសមត្ថកិច្ចត្រូវបង្ខំឲ្យម្ចាស់សំណង់បញ្ចប់ការងារជួសជុលនេះក្នុងរយៈពេលមួយជាកំណត់ អាស្រ័យលើទំហំការងារ និងការវាយតម្លៃជាក់ស្តែងរបស់មន្ត្រីជំនាញ ដើម្បីរក្សានូវសោភ័ណភាព សុវត្ថិភាពការដ្ឋាននិងសណ្តាប់ធ្នាប់សាធារណៈ ។

## ជំពូកទី៤
## ការត្រួតពិនិត្យការដ្ឋានជួសជុល ភារកិច្ចរបស់ម្ចាស់សំណង់ និងបណ្តឹងតវ៉ា

### ប្រការ១៦.-

ស្ថាប័នមានសមត្ថកិច្ចមានសិទ្ធិត្រួតពិនិត្យតាមដានការដ្ឋានជួសជុលនិងឯកសារពាក់ព័ន្ធនឹងការជួសជុលបានគ្រប់ពេលវេលា។ បើពិនិត្យឃើញថា ការជួសជុលមិនស្របតាមលិខិតអនុញ្ញាតជួសជុល និងមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសជំនាញ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ឬអគ្គនាយកដ្ឋានសំណង់ ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាបន្ទាន់ឲ្យស្របតាមលិខិតអនុញ្ញាតជួសជុលនិងតាមបទដ្ឋានបច្ចេកទេសជំនាញ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមធ្វើតាមការណែនាំខាងលើនេះ ស្ថាប័នជំនាញមានសិទ្ធិបញ្ឈប់ការជួសជុល ឬចេញលិខិតផ្អាកការដ្ឋាន និងឲ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាលើកទី២ឲ្យបានត្រឹមត្រូវក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតណែនាំជាផ្លូវការ។

ប្រសិនបើម្ចាស់សំណង់ នៅតែរឹងរូសមិនព្រមអនុវត្តទៅតាមការណែនាំខាងលើនេះ មន្ត្រីជំនាញមានសិទ្ធិស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយដល់ការអនុវត្តន៍ឲ្យមានប្រសិទ្ធភាព។

### ប្រការ១៧.-

ត្រូវបានហាមឃាត់ ៖

- ការដាក់តាំងគរសម្ភារៈសំណង់លើផ្លូវសាធារណៈ
- ការតាំងការដ្ឋានលយទៅលើចិញ្ចើមផ្លូវសាធារណៈលើសពីពីរភាគបីនៃចិញ្ចើមផ្លូវ
- ការបង្ហូរនិងការចោលកាកសំណល់ពីការដ្ឋានសំណង់មកផ្លូវនិងទីសាធារណៈ ។

ម្ចាស់ការដ្ឋានសំណង់ត្រូវ ៖

- ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ក្នុងរយៈពេលដំណើរការជួសជុល
- រុះរើ សម្អាតការដ្ឋានជួសជុល និងយកចេញនូវសម្ភារៈបរិក្ខាគ្រឿងចក្រ និងកាកសំណល់ពីការដ្ឋានជួសជុលក្នុងរយៈយ៉ាងយូរពីរសប្តាហ៍ក្រោយពេលចប់ការងារជួសជុល ។

### ប្រការ១៨.-

ក្នុងពេលដំណើរការជួសជុល ម្ចាស់សំណង់និងអ្នកពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងវិវាទផ្សេងៗដែលបណ្តាលមកពីការធ្វេសប្រហែស ឬការជួសជុលមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសសំណង់ ។

### ប្រការ១៩.-

ក្នុងករណីមានបណ្តឹងតវ៉ាដែលទាក់ទងនឹងការស្នើសុំជួសជុលឬការជួសជុល អ្នកប្តឹងតវ៉ាអាចប្តឹងទៅស្ថាប័នមានសមត្ថកិច្ចចេញលិខិតអនុញ្ញាតជួសជុលឲ្យជួយដោះស្រាយទំនាស់ ។ ស្ថាប័នមានសមត្ថកិច្ចត្រូវផ្អាកដំណើរការនៃការស្នើសុំលិខិតអនុញ្ញាតជួសជុលឬផ្អាកការជួសជុលជាបណ្តោះអាសន្នសិន ដើម្បីធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់នេះ ។

ក្នុងករណីដែលការសម្របសម្រួលខាងលើមិនអាចធ្វើបាន អ្នកប្តឹងតវ៉ាអាចប្តឹងទៅតុលាការដើម្បីដោះស្រាយតាមនីតិវិធីនៃច្បាប់ ។

## ជំពូកទី៥
## អំពីសំណង់ចាស់

**ប្រការ២០.-**

រាល់សំណង់អគារចាស់ទ្រុឌទ្រោមមិនអាចស្នាក់នៅបាន និងអាចបង្កគ្រោះថ្នាក់ដោយប្រការណាមួយដែលមានការវាយតម្លៃច្បាស់លាស់ពីស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចតាមសំណើរបស់ស្ថាប័នជំនាញត្រូវជូនដំណឹងដល់ម្ចាស់សំណង់ ឬកម្មសិទ្ធិករដែលស្នាក់នៅក្នុងអគារនោះ ដោយបង្ខំឲ្យធ្វើការរុះរើ ឬជួសជុលជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងជៀសវាងគ្រោះថ្នាក់ជាយថាហេតុ ។ ការជួសជុលត្រូវធ្វើឲ្យស្របតាមបទដ្ឋានបច្ចេកទេសសំណង់ ។

ក្នុងករណីដែលម្ចាស់សំណង់មិនព្រមជួសជុលតាមសេចក្តីជូនដំណឹងខាងលើចំនួន២(ពីរ)ដង ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាតឬគ្រោះថ្នាក់ទាំងឡាយដែលកើតឡើងដោយការមិនព្រមជួសជុលសំណង់របស់ខ្លួន ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២១.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ២២.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ.កុម្ភៈ. ឆ្នាំ២០១៣

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលារាជធានីខេត្ត
- ដូចប្រការ២១
- ឯកសារ-កាលប្បវត្តិ